Australian Government

help confidential assistance understanding children progress support youth solutions safe counselling

# កម្មវិធីជួយឧបត្ថម្ភកូនក្រោយការនៅបែកគ្នា

រដ្ឋាភិបាលអូស្ត្រាលី បានផ្តល់ជំនួយហិរញ្ញវត្ថុដល់កម្មវិធីឧបត្ថម្ភកូនក្រោយការនៅបែកគ្នា ដើម្បីជួយដល់កុមារ និងជំទង់ ដែលត្រូវការការជួយឧបត្ថម្ភ នៅពេលដែលឪពុកម្តាយរបស់គេបាននៅបែកគ្នា។

## តើកម្មវិធីជួយឧបត្ថម្ភកូនក្រោយការនៅបែកគ្នាជាអ្វី?

កម្មវិធីជួយឧបត្ថម្ភកូនក្រោយការនៅបែកគ្នា ផ្តល់ការជួយឧបត្ថម្ភសម្រាប់កុមារ និងជំទង់គ្រប់អាយុ ដែលត្រូវការជំនួយមួយចំនួន ដើម្បីដោះស្រាយ និងស្វែងយល់ពីការនៅបែកគ្នារបស់ឪពុកម្តាយរបស់ពួកគេ។

កម្មវិធីនេះជួយកុមារនិងជំទង់ដោះស្រាយវិបត្តិដែលកើតមានឡើងពីភាពល្អក់កករក្នុងទំនាក់ទំនងឪពុកម្តាយរបស់ពួកគេ និងជួយពួកគេដោះស្រាយបញ្ហាផ្ទាល់ខ្លួនដែលពួកគេជួបប្រទះ។ កម្មវិធីនេះជួយពួកគេឲ្យសម្របទៅនឹងការប្រែប្រួលផ្សេងៗដែលកើតឡើងពីការនៅបែកគ្នារបស់ឪពុកម្តាយ និងដើម្បីឲ្យពួកគេអាចបង្ហាញពីអារម្មណ៍និងគំនិតរបស់ពួកគេទាក់ទងនឹងការនៅបែកគ្នានេះ។

កម្មវិធីជួយឧបត្ថម្ភកូនបន្ទាប់ពីការនៅបែកគ្នា ផ្តល់ឱកាសសម្រាប់កុមារនិងជំទង់ឲ្យចូលរួមក្នុងការសម្រេចចិត្តដែលទាក់ទងនឹងផលប៉ះពាល់ដែលកើតមានចំពោះពួកគេ កើតចេញពីការនៅបែកគ្នារបស់ឪពុកម្តាយពួកគេ។ នៅពេលដែលកុមារអាចនិយាយពីបញ្ហាដែលជះឥទ្ធិពលដល់ការសម្រេចចិត្តពីជោគវាសនារបស់ពួកគេ នោះមានន័យថាសមត្ថភាពនៃការគ្រប់គ្រងភាពតានតឹងក្នុងអារម្មណ៍ដែលកើតចេញពីការនៅបែកគ្នារបស់ឪពុកម្តាយក៏មានលក្ខណៈល្អប្រសើរជាងមុនដែរ។

កុមារនិងជំទង់អាចរកកម្មវិធីនេះបានគ្រប់ពេលវេលា នៅក្នុងអំឡុងពេលនិងក្រោយពេលនៃដំណើរការនៃការនៅបែកគ្នា។

## តើធ្វើដូចម្តេចទើបដឹងថាកូនរបស់ខ្ញុំត្រូវការជំនួយ?

ពេលខ្លះវាពិបាកនឹងប្រាប់អ្នកថាកូនរបស់អ្នកត្រូវការ ជំនួយ។ ប្រសិនបើកូនរបស់អ្នកនៅតែបន្តមានអារម្មណ៍សៅហ្មង ខឹង ឬកើតទុក្ខ អ្នកប្រហែលជាត្រូវការរកអ្នកណាម្នាក់ដែលអាចនិយាយជាមួយកូនរបស់អ្នក។ ប្រសិនបើអាកប្បកិរិយារបស់កូនអ្នកមានការផ្លាស់ប្តូរជាច្រើនអំឡុងពេល និងក្រោយពេលដំណើរការនៃការនៅបែកគ្នា ពួកគេប្រហែលជាត្រូវការជំនួយបន្ថែមខ្លះៗ ដើម្បីជួយពួកគេឲ្យយល់ដឹងពីរឿងដែលកើតមានឡើង។

កុមារនិងជំទង់គ្រប់រូប ត្រូវការពេលវេលាដើម្បីសម្របទៅនឹងស្ថានភាពថ្មី ប៉ុន្តែប្រសិនបើអ្នកព្រួយបារម្ភថាអ្វីៗប្រព្រឹត្តទៅមិនសូវល្អ អ្នកអាចស្នើសុំជំនួយបាន។

## ចុះប្រសិនបើខ្ញុំមានអារម្មណ៍ថាគ្មានសុវត្ថិភាព ឬខ្ញុំគិតថាកូនរបស់ខ្ញុំមិនមានសុវត្ថិភាព?

ប្រសិនបើអ្នកមានការព្រួយបារម្ភពីសុវត្ថិភាពរបស់អ្នក ឬសុវត្ថិភាពរបស់កូនអ្នក អ្នកត្រូវផ្តល់ដំណឹងនេះទៅដល់បុគ្គលិកឲ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ អង្គការដែលធ្វើការងារទាក់ទងនឹងកម្មវិធីនេះ បានរៀបចំកន្លែងមានសុវត្ថិភាពសម្រាប់អតិថិជន និងបុគ្គលិករួចជាស្រេច។

## តើវាត្រូវចំណាយលើអ្វីខ្លះ?

អ្នកត្រូវបង់ថ្លៃកម្មវិធីជួយឧបត្ថម្ភកូនបន្ទាប់ពីការនៅបែកគ្នា តម្លៃគឺអាស្រ័យលើស្ថានភាពហិរញ្ញវត្ថុរបស់អ្នក។ អ្នកអាចប្រាប់បុគ្គលិកថា អ្នកជាអ្នកមានប្រាក់ចំណូលទាប ឬធ្លាប់ជួបវិបត្តិហិរញ្ញវត្ថុ ដូច្នេះពួកគេនឹងធ្វើឲ្យប្រាកដថាកូនរបស់អ្នកអាចប្រើប្រាស់កម្មវិធីបាន។

## តើមានអ្វីកើតឡើងចំពោះកម្មវិធីជួយឧបត្ថម្ភកូនបន្ទាប់ពីការនៅបែកគ្នា?

កម្មវិធីនេះអាចជួយកុមារនិងជំទង់បានច្រើនបែប រួមមាន ផ្តល់ការគាំទ្រដើម្បីឲ្យពួកគេយល់ដឹងពីអ្វីដែលកំពុងកើតមានចំពោះខ្លួនពួកគេផ្ទាល់ និងចំពោះគ្រួសារ នៅក្នុងអំឡុងពេល និងក្រោយពេលនៃការនៅបែកគ្នារបស់ឪពុកម្តាយពួកគេ។ នេះអាចរួមមានការប្រឹក្សាយោបល់ជាលក្ខណៈបុគ្គល ឬជាក្រុមជាមួយក្មេងៗដែលមានអាយុប្រហាក់ប្រហែលគ្នា។

ការជួយគ្នាតាមរយៈមិត្តភក្តិនេះ ជួយឲ្យកុមារនិងជំទង់ស្វែងយល់ពីការប្រែប្រួលនៅក្នុងការរៀបចំរបស់គ្រួសារពួកគេ និងជួយគាំទ្រពួកគេឆ្លងកាត់ការផ្លាស់ប្តូរនេះ។ វាក៏បានជួយពួកគេឲ្យដឹងថាមិនតែពួកគេទេដែលមានបញ្ហានេះ ប៉ុន្តែមានក្មេងៗដទៃទៀតក៏ជួបបញ្ហាដូចពួកគេដែរ ហើយវាផ្តល់ភាពកក់ក្តៅនៅក្នុងស្ថានភាពដែល

គេជួបប្រទះ។ ការជួយគ្នាតាមរយៈមិត្តភក្តិអាចផ្តល់វិធីសាស្ត្រមានប្រយោជន៍នានាដល់កុមារនិងជំទង់ក្នុងការគ្រប់គ្រងការឈឺចាប់ និងស្ត្រេស ដែលកើតឡើងដោយសារការនៅបែកគ្នារបស់ឪពុកម្តាយពួកគេ។

កូនរបស់អ្នកក៏អាចចូលរួមផ្តល់ជាគំនិត និងបង្ហាញពីអារម្មណ៍ ដែលគេមានចំពោះអ្នក ឬក៏ពួកគេអាចផ្តល់ព័ត៌មានដែលមានប្រយោជន៍មួយចំនួន។ កម្មវិធីជួយឧបត្ថម្ភកូនបន្ទាប់ពីការនៅបែកគ្នា ជួយកុមារនិងជំទង់ឲ្យទទួលបានបំណិនជីវិតនិងសង្គម ដែលនឹងជួយពួកគេឲ្យតស៊ូក្នុងឆាកជីវិតរបស់ពួកគេ។

កម្មវិធីត្រូវបានបង្កើតឡើងដើម្បីជួយគាំទ្រដល់គ្រួសារដែលស្ថានភាពផ្សេងៗគ្នា។ ពុំមានកម្មវិធីណាមួយដែលដូចគ្នាសម្រាប់កូនអ្នកនោះទេ ពីព្រោះកុមារមានតម្រូវសេវាឧបត្ថម្ភគាំទ្រខុសគ្នាដែលអាចមាននៅក្នុងកម្មវិធីនេះ។

## តើកម្មវិធីជួយឧបត្ថម្ភកូនបន្ទាប់ពីការនៅបែកគ្នាធ្វើឡើងសម្រាប់អ្នកណា?

អ្នកដែលមានអាយុក្រោម 18 ឆ្នាំ អាចប្រើប្រាស់កម្មវិធីនេះបាន។ មានសកម្មភាពជាច្រើនត្រូវបានបង្កើតឡើងសម្រាប់តម្រូវតាមមនុស្សគ្រប់អាយុនិងវ័យពីកុមាររហូតដល់ជំទង់។ ជំទង់មិនធ្វើអ្វីដូចជាកុមាតូចៗនោះទេ ឬធ្វើការជាក្រុមជាមួយកុមារនោះឡើយ ប៉ុន្តែបងប្អូនស្រីប្រុសរបស់ពួកគេអាចចូលក្នុងការជួបប្រជុំគ្នាដើម្បីចែករំលែកពីអារម្មណ៍ និងគំនិតរបស់ពួកគេ។

ឪពុកម្តាយដែលបាននៅបែកគ្នា គួរធ្វើការលើកទឹកចិត្តកូនរបស់ពួកគេនៅគ្រប់វ័យ ឲ្យប្រើប្រាស់សេវានេះដើម្បីជួយពួកគេឲ្យបានយល់ដឹងពីការរស់នៅបែកគ្នានៅក្នុងគ្រួសារ។

## តើមានជំនួយអ្វីខ្លះសម្រាប់ខ្ញុំនិងសមាជិកគ្រួសារខ្ញុំទាំងអស់?

មានកម្មវិធីផ្សេងទៀតសម្រាប់មនុស្សពេញវ័យ។ ប្រសិនបើអ្នកត្រូវការជំនួយសម្រាប់ខ្លួនអ្នកផ្ទាល់ បុគ្គលិកនៅក្នុងកម្មវិធីនេះ អាចណែនាំអំពីកម្មវិធីមួយចំនួនដែលសមស្របសម្រាប់អ្នក។ សមាជិកគ្រួសារដទៃទៀតដូចជាជីដូនជីតា ឬអ្នកថែទាំ ក៏អាចណែនាំឲ្យប្រើប្រាស់សេវាគាំទ្រនេះផងដែរ។

អ្នកក៏អាចចូលទៅកាន់សេវាទំនាក់ទំនងគ្រួសារតាមប្រព័ន្ធអ៊ីនធ័រណើតតាមរយៈអាសយដ្ឋាន www.familyrelationships.gov.au ដើម្បីទទួលបានព័ត៌មានបន្ថែមទៀត។

## តើអ្វីដែលកូនខ្ញុំបាននិយាយនៅឯកម្មវិធីជួយឧបត្ថម្ភកូន បន្ទាប់ពីការនៅបែកគ្នាត្រូវបានរក្សាជាការសម្ងាត់ដែរឬទេ?

បាទ/ចាស៎ អ្វីដែលកូនរបស់អ្នកបាននិយាយនៅក្នុងការជួបប្រជុំប្រឹក្សាយោបល់គ្នានឹងត្រូវរក្សាការសម្ងាត់។

ប្រសិនបើកូនរបស់អ្នកប្រាថ្នាចង់ប្រាប់អ្នករឿងគ្រប់យ៉ាងដែលបានពិភាក្សាគ្នាក្នុងអំឡុងពេលនៃកម្មវិធី នោះអ្នកប្រឹក្សាយោបល់នឹងអនុញ្ញាតឲ្យពួកគេធ្វើវា។ មាត្រានៃច្បាប់គ្រួសារចែងថា អ្វីដែលបាននិយាយនៅក្នុងការប្រឹក្សាយោបល់ស្តីពីគ្រួសារនឹងត្រូវរក្សាជាការសម្ងាត់។ អ្នកអាចជជែកអំពីឯកជនភាព ឬការយល់ព្រមជាមួយអ្នកដឹកនាំកម្មវិធីនេះបាន។

អ្នកប្រឹក្សាយោបល់អាចនិយាយប្រាប់អ្នកណាម្នាក់ផ្សេងទៀត អំពីអ្វីដែលកូនរបស់អ្នកបាននិយាយ ប្រសិនបើគេគិតថាមានការគម្រាមកំហែងដល់សុខភាព និងសុវត្ថិភាពរបស់នរណាម្នាក់។

អ្នកប្រឹក្សាយោបល់ត្រូវរាយការណ៍អំពីករណីនៃការរំលោភបំពានលើកុមារ ឬក្នុងករណីដែលមានការប្រឈមនឹងការរំលោភបំពានទៅដល់អាជ្ញាធរមានសមត្ថកិច្ច។

## តើខ្ញុំធ្វើទំនាក់ទំនងជាមួយ កម្មវិធីជួយឧបត្ថម្ភកូនក្រោយការនៅបែកគ្នាយ៉ាងដូចម្តេច?

អ្នកអាចទូរសព្ទទៅកាន់ខ្សែទូរសព្ទផ្តល់ប្រឹក្សាអំពីទំនាក់ទំនងគ្រួសារ តាមរយៈលេខ **1800 050 321** ពីម៉ោង **8ព្រឹក ដល់ 8យប់** ពីថ្ងៃចន្ទ **ដល់ថ្ងៃសុក្រ** និងពីម៉ោង **10ព្រឹក ដល់ 4ល្ងាច នៅថ្ងៃសៅរ៍** (លើកលែងតែថ្ងៃបុណ្យជាតិប៉ុណ្ណោះ)។ ពួកគេអាចជួយអ្នកស្វែងរកកម្មវិធីដែលជិតអ្នកបំផុតដើម្បីជួយដល់អ្នក។ ប្រសិនបើពុំមានកម្មវិធីជួយឧបត្ថម្ភកូនបន្ទាប់ពីការនៅបែកគ្នានៅជិតអ្នកនោះទេ នោះខ្សែទូរសព្ទផ្តល់ប្រឹក្សានឹងប្រាប់អ្នកពីសេវាដែលមានប្រយោជន៍ដទៃផ្សេងទៀតដែលស្ថិតនៅជិតអ្នក។

អ្នកក៏អាចចូលទៅកាន់សេវាទំនាក់ទំនងគ្រួសារតាមប្រព័ន្ធអ៊ីនធ័រណេត តាមរយៈអាសយដ្ឋាន www.familyrelationships.gov.au ដើម្បីស្វែងយល់បន្ថែមអំពីសេវាទំនាក់ទំនងគ្រួសារផ្សេងទៀត។ គេហទំព័រនេះមានព័ត៌មានដែលមានប្រយោជន៍ជាច្រើនទាក់ទងនឹងគ្រួសារនិងបញ្ហាផ្សេងៗទៀត។